**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួង

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ៈ ១៩៩ ប្រ.ក

រាជធានីភ្នំពេញ. ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ

## របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត ក្រុង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់ក្រសួង

## សម្រេច

**ប្រការ ១.-**

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង ជាអង្គភាពស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមានតួនាទីជាសេនាធិការរបស់ក្រសួង និងជំនួយការអោយអភិបាលខេត្ត ក្រុង ក្នុងការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យវប្បធម៌ និងវិចិត្រសិល្បៈនៅខេត្ត ក្រុង ។

**ប្រការ ២.-**

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង មានភារកិច្ចដូចតទៅ ÷

- ទំនាក់ទំនងការងារ រវាងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង ជាមួយអង្គភាពចំណុះក្រសួង និងបណ្តាមន្ទីរនានាជុំវិញខេត្ត ក្រុង គឺជាទំនាក់ទំនងសហការ ជួយឧបត្ថម្ភគ្នាទៅវិញទៅមក

- ទំនាក់ទំនងការងាររវាងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង ជាមួយបណ្តា ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ខ័ណ្ឌ ស្រុក ជាទំនាក់ទំនងខ្សែបណ្តោយ ។

**ប្រការ ៥.-**

រចនាសម្ព័ន្ធរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង រួមមាន ៧ ការិយាល័យ :

ក. ការិយាល័យ រដ្ឋបាល បុគ្គលិក

ខ. ការិយាល័យ សិល្បៈទស្សនីយភាព

គ. ការិយាល័យ អភិវឌ្ឍន៍វប្បធម៌

ឃ. ការិយាល័យ សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌

ង. ការិយាល័យ បេតិកភណ្ឌ

ច. ការិយាល័យ សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

ឆ. ការិយាល័យ សារមន្ទីរ

ដោយឡែកនៅតាមបណ្តាស្រុក ខ័ណ្ឌមានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុក ខ័ណ្ឌ ជាអង្គភាពទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពវប្បធម៌ក្នុងមូលដ្ឋាន ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធាន មួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៦.-**

ភារកិច្ចជាគោលរបស់ការិយាល័យនីមួយៗ មានដូចតទៅ :

ក. ការិយាល័យ រដ្ឋបាល បុគ្គលិក

- គ្រប់គ្រងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានា ពាក់ព័ន្ធលើវិស័យវប្បធម៌
- គ្រប់គ្រងការងារឯកសារ លិខិតចេញ លិខិតចូលគ្រប់ប្រភេទ
- គ្រប់គ្រងសំរបសំរួលការងាររដ្ឋបាល ផែនការ ស្ថិតិ និងសរុប
- គ្រប់គ្រងការងារបុគ្គលិក ការងារក្របខ័ណ្ឌ និងបណ្តុះបណ្តាល
- គ្រប់គ្រងការងារផែនការ គណនេយ្យ ថវិកា សម្ភារៈ និងបរិក្ខារ
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ។

ខ. ការិយាល័យ សិល្បៈទស្សនីយភាព

- បង្កើតស្នាដៃ និងផ្សព្វផ្សាយវប្បធម៌ជាតិ និងជនជាតិ តាមរយៈការសម្តែងទស្សនីយភាពសិល្បៈ
- សិក្សា ស្រាវជ្រាវ អំពីសិល្បៈវប្បធម៌របស់ជាតិ និងជនជាតិ

- គ្រប់គ្រងក្រុមសិល្បៈក្នុងខេត្ត ក្រុង
- គ្រប់គ្រងការធ្វើអាជីវកម្ម និងផ្តល់សេវាកម្ម ពាក់ព័ន្ធនឹងសកម្មភាពសិល្បៈទស្សនីយភាព
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ។

**គ. ការិយាល័យ អភិវឌ្ឍន៍វប្បធម៌**

- គ្រប់គ្រងការធ្វើអាជីវកម្ម និងផ្តល់សេវាកម្ម ទាក់ទងនឹងពិធីជាប្រពៃណី ទំនៀមទំលាប់ អក្សរសាស្ត្រ អក្សរសិល្ប៍ជាតិ
- សិក្សាស្រាវជ្រាវអំពីវប្បធម៌ ប្រពៃណីទំនៀមទម្លាប់ជាតិ និងជនជាតិ ។
- បំផុសលើកទឹកចិត្តមហាជន ប្រជាជន អោយចូលរួមក្នុងសកម្មភាពវប្បធម៌ ល្បែងកំសាន្ត ល្បែងប្រជាប្រិយ ការរៀបចំភូមិដ្ឋាន របៀបរបបរស់នៅល្អ ការរៀបចំពិធីបុណ្យប្រពៃណីជាតិ ជនជាតិ ការតាំងពិព័រណ៍ ការប្រឡងប្រជែង ... ។ល ។
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ។

**ឃ. ការិយាល័យ សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌**

- ផ្សព្វផ្សាយ និងណែនាំដល់អាជីវករភាពយន្ត វីដេអូ នូវរាល់សារាចរ សេចក្តីជូនដំណឹងផ្សេងៗរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ទទួលចុះបញ្ជីរាល់ខ្សែភាពយន្ត វីដេអូ ដែលមានទិដ្ឋាការចេញដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- គ្រប់គ្រង តាមដាន ត្រួតពិនិត្យ សកម្មភាពអាជីវកម្មភាពយន្ត វីដេអូ ខារ៉ាអូខេ និងគ្រប់សកម្មភាព ដែលនាំដល់ការបណ្តុះស្មារតី និងបញ្ហា ( ទូរទស្សន៍តុក្កតា-ហ្គេម )
- ដោះស្រាយបទល្មើសភាពយន្ត វីដេអូ ដែលកើតមាននៅក្នុងខេត្ត ក្រុង របស់ខ្លួនតាមលក្ខការណ៍ច្បាប់
- គ្រប់គ្រងការធ្វើអាជីវកម្ម និងផ្តល់សេវាកម្មភាពយន្ត វីដេអូ និងខារ៉ាអូខេ
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ។

**ង. ការិយាល័យ បេតិកភណ្ឌ**

- គ្រប់គ្រង ថែរក្សា ការពារលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ និងជនជាតិ ប្រាង្គប្រាសាទ រមណីយដ្ឋាន ប្រវត្តិសាស្ត្រ វត្ថុបុរាណ បេតិកភណ្ឌធម្មជាតិ
- រៀបចំអភិរក្សដ្ឋាន ទុកដាក់ ចុះបញ្ជីវត្ថុបុរាណ មិនអោយបាត់បង់ ឬខូចខាត

- រៀបចំការចុះបញ្ជីសារពើភ័ណ្ឌសំណង់បូរាណ និងស្ថានីយប្រវត្តិសាស្ត្រទាំងអស់ដែលមានក្នុងទឹកដី ខេត្ត ក្រុង របស់ខ្លួន
- សហការជាមួយផ្នែកមានសមត្ថកិច្ចទប់ស្កាត់រាល់បទល្មើស ទាក់ទងបេតិកភណ្ឌវប្បធម៌ជាតិ
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង។

**ច. ការិយាល័យ សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម**

- សិក្សា ស្រាវជ្រាវចងក្រងឯកសារ អំពីទំរង់សិល្បៈបុរាណ សម័យ និងវិជ្ជាឯកទេសសិប្បកម្ម
- បណ្តុះបណ្តាលវិជ្ជាជីវៈសិល្បៈសិប្បកម្ម និងសិល្បៈសូនរូប
- គ្រប់គ្រងផលិតកម្ម អាជីវកម្ម សេវាកម្ម ផ្នែកសិប្បកម្មផលិតវត្ថុសិល្បៈ និងផ្នែកសិល្បៈសូនរូប ដែលទាក់ទងទៅនឹងចម្លាក់ តម្បាញ ប៉ាក់ខិន គំនូរ ការតែងលំអរ
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង។

**ឆ. ការិយាល័យសារមន្ទីរ**

- គ្រប់គ្រងការចុះបញ្ជីសារពើភណ្ឌការងារអភិរក្ស និងការទុកដាក់វត្ថុសិល្បៈនៅក្នុងសារមន្ទីរ និងនៅតាមកន្លែងផ្សេងៗទៀត ដែលរក្សាទុកសម្បត្តិវប្បធម៌
- បំផុសការអប់រំផ្សព្វផ្សាយ អំពីបេតិកភណ្ឌវប្បធម៌ជាតិ ឱ្យបានទទួលទូលាយដល់ស្រទាប់ប្រជាពលរដ្ឋតាមរយៈការសិក្សាស្រាវជ្រាវ និងដាក់តាំងបង្ហាញសមុច្ច័យទាំងឡាយ ជូនសាធារណជនទស្សនា
- សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា សំដៅចលនាសិស្ស-និស្សិត ឱ្យចូលទស្សនាសារមន្ទីរគ្រប់កំរិតសិក្សា
- ធ្វើផែនការ និងលើកទិសដៅការងាររៀបចំ និងអភិវឌ្ឍន៍សារមន្ទីរ
- បង្កើត និងផ្តល់សេវាកម្មផ្នែកសារមន្ទីរ
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង។

**ជ. ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ខណ្ឌ ស្រុក**

- គ្រប់គ្រង ការពារ ថែរក្សាសម្បត្តិវប្បធម៌ ដែលមានក្នុងស្រុក ខណ្ឌ
- សហការជាមួយរដ្ឋអំណាចមូលដ្ឋាន ដើម្បីទប់ស្កាត់រាល់សកម្មភាពបំផ្លាញសម្បត្តិវប្បធម៌ជាតិ សកម្មភាពផ្សព្វផ្សាយភាពយន្តវីដេអូ ដែលប៉ះពាល់ដល់ទំនៀមទម្លាប់ និងប្រពៃណីជាតិ ជាដើម
- បំផុសប្រជាជន មហាជនក្នុងមូលដ្ឋានចូលរួមក្នុងសកម្មភាពវប្បធម៌ និងការរៀបចំពិធីបុណ្យប្រពៃណីជាតិ ជាដើម

- បំផុសប្រជាជន មហាជនក្នុងមូលដ្ឋានចូលរួមក្នុងសកម្មភាពវប្បធម៌ និងការរៀបចំពិធីបុណ្យប្រពៃណីជាតិ ជាដើម ។
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំមន្ទីរប្រគល់ជូន
- អនុវត្តរបបរាយការណ៍ទៀងទាត់ ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ។

**ប្រការ ៧.-**

- ការបង្កើត និងរំសាយការិយាល័យត្រូវកំណត់ដោយប្រកាសក្រសួង
- តួនាទី ភារកិច្ចលម្អិតរបស់បណ្ដាការិយាល័យ អាស្រ័យដោយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ក្រុង ជាអ្នកកំណត់ ដោយសេចក្តីសំរេចមួយដោយឡែក ។

**ប្រការ ៨.-**

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង ជាអង្គភាពអនុវត្តរបបហិរញ្ញវត្ថុបុព្វហេតុរដ្ឋបាល ។

**ប្រការ ៩.-**

បទប្បញ្ញត្តិនៃប្រកាសលេខ១០០ប្រក.វវស.បុ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៩ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០.-**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្ម អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**វេង សេរីវុឌ្ឍ**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុង

“ ដើម្បីជូនជ្រាបជាព័ត៌មាន ”

- ដូចប្រការ ១០ “*ដើម្បីអនុវត្តន៍*”
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត ក្រុង

**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ក្រុង**

- ការិយាល័យ រដ្ឋបាល បុគ្គលិក
- ការិយាល័យ សិល្បៈទស្សនីយភាព
- ការិយាល័យ អភិវឌ្ឍន៍វប្បធម៌
- ការិយាល័យ សិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌
- ការិយាល័យ បេតិកភណ្ឌ
- ការិយាល័យ សិល្បៈសូនរូប និងសិប្បកម្ម
- ការិយាល័យ សារមន្ទីរ
- ការិយាល័យ វប្បធម៌ និងវិចិត្រសិល្បៈ ខណ្ឌ ស្រុក